# ការសម្ភាសរបស់អ៊ុំស្រី សេន ស៊ីណា

កៈ អ្នកសម្ភាសឈ្មោះ ញ៉ែម លាភី ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ សេន ស៊ីណា

## <u>ប្រវត្តិសង្ខេបរបស់អ៊ុំស្រី សេន ស៊ីណា</u>

អ្នកមីង សេន ស៊ីណា គាត់គឺជាស្ត្រីម្នាក់ដែលតស៊ូនៅក្នុងឆាកជីវិត។ គាត់ខំប្រឹងប្រែងរកស៊ីរបរលក់ត្រី និង បេះបន្លែដើម្បីចិញ្ចឹមគ្រួសារ។ អ្នកមីងបានឆ្លងកាត់នៅក្នុងរបប សង្គ្រាមប៉ុលពតហើយនៅក្នុងសង្គ្រាមនោះគឺបានធ្វើឱ្យអ្នកមីងពិបាកខ្លាំងបំផុតដែលឱ្យគាត់ធ្វើការយ៉ាងខ្លាំងដូចជារែកដី លើកទំនប់ ស្ទូងស្រូវ និង ធ្វើការងារជាច្រើនទៀតប៉ុន្តែមិនបានឱ្យគាត់ហូបគ្រប់គ្រាន់ទេ គឺឱ្យហូបបបរដំឡូង បបរពោត ហើយមានលាយគ្រាប់អង្ករបន្តិចបន្តួច។ បងប្អូនរបស់អ្នកមីងត្រូវបានពួកប៉ុលពតយកទៅសម្លាប់ចោលប៉ុន្តែកុហកថាឲ្យទៅធ្វើការនៅកន្លែងផ្សេង ប៉ុន្តែតាមការពិតគឺយកទៅសម្លាប់ចោលតែប៉ុណ្ណោះ។ មុខរបរនៅក្នុងគ្រួសាររបស់អ្នកមីង គឺគាត់តាំងពីម្ដាយឪពុកគឺជាអ្នកនេសាទនិងលក់ត្រី។ ហើយអ្នកមីងបានរៀបការជាមួយនឹងស្វាមីនៅឆ្នាំ ១៩៨៣ បន្ទាប់ពេលបែកសង្គ្រាមហើយបានប៉ុន្មានឆ្នាំហើយក៏បានមានកូនចៅហើយកូនច្បងរបស់គាត់ត្រូវបានស្លាប់ដោយបន្សល់ទុកនូវចៅ៩នាក់ដើម្បីឱ្យគាត់មើល កូនរបស់គាត់ស្លាប់ដោយសារលង់ទឹក ហើយស្វាមីបានយកប្រពន្ធមួយទៀត ហើយទុកកូនឲ្យអ្នកមីងមើល។ អ្នកមីងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីជួយទំនុកបម្រុងទាំងកូន ហើយនិងចៅជាមួយនឹងស្វាមីរបស់គាត់។

កៈ សូមជម្រាបសួរអ្នកមីង! នាងខ្ញុំឈ្មោះ ញ៉ែម លាភី ហើយសូមអរគុណអ្នកមីងដែលបានអនុញ្ញាតឲ្យខ្ញុំសម្ភាសអ្នកមីងនៅក្នុងថ្ងៃនេះ ហើយការសម្ភាសនេះត្រូវបានធ្វើឡើងនៅក្នុងភូមិទំនប់កៅប្អូន វត្តទួលតាម៉ក់ ខេត្តកណ្ដាល ហើយការសម្ភាសនេះគឺនៅក្នុងថ្ងៃសៅរ៍ ២២ ខែ  មិថុនា ឆ្នាំ ២០១៨ ហើយអ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ខ្ញុំឈ្មោះ សេន ស៊ីណា។

កៈ សេន ស៊ីណា!

ខៈ ចា៎!

កៈ អ្នកមានកើតនៅក្នុងឆ្នាំណាដែរ?

ខៈ ខ្ញុំកើតនៅក្នុងឆ្នាំ ១៩៦៣។

កៈ ៦៣ (១៩៦៣)!

ខៈ ចា៎!

កៈ អ្នកមីងមានចាំថ្ងៃខែ?

ខៈ ចាំទេតើ! ខ្ញុំកើតថ្ងៃអាទិត្យទី៧ ខែ៧ យើងហ្នឹងណា៎។

កៈ ចា៎ ខែ៧!

ខៈ ចា៎!

កៈ ចា៎! ហើយស្រុកកំណើតរបស់អ្នកមាននៅឯណាដែរ?

ខៈ ស្រុកកំណើតខ្ញុំនៅភូមិទំនប់ ៩៤ ទួលតាម៉ក់។ ខ្ញុំកើតខ្ញុំនៅទីហ្នឹងតែម្តង។

កៈ ចា៎! នៅទីហ្នឹង ហើយអ្នកមីងកើតនៅទីហ្នឹង ប៉ុន្តែចុះសព្វថ្ងៃអ្នកមីងនៅឯណា?

ខៈ ឥឡូវនេះខ្ញុំនៅគេហៅថាភូមិ៩៤ គេហៅថាភូមិ៩៤ គេផ្លាស់ពីទួលតាម៉ក់ គេហៅទំនប់៩៤ ណា៎ កាលពេលសង្គមមកគេហៅថាទួលតាម៉ក់ បច្ចុប្បន្នឥឡូវនេះគេហៅថាភូមិ៩៤ ចា៎។

កៈ ចា៎! ប៉ុន្តែកន្លែងដដែលទេ?

ខៈ ចា៎! កន្លែងដដែលទេ។

កៈ គ្រាន់តែគេប្តូរ។

ខៈ ចា៎! គ្រាន់តែគេប្តូរ។

កៈ ចា៎!

ខៈ ហ្នឹងហើយ។

កៈ អ្នកមីងឆ្នាំអីគេដែរឆ្នាំខ្មែរ?

ខ៖ ខ្ញុំឆ្នាំខ្មែរឆ្នាំថោះ។

ក៖ ឆ្នាំថោះ ចា៎។ ឆ្នាំដូចខ្ញុំដែរខ្ញុំឆ្នាំផងដែរ។ មីងមានឈ្មោះហៅខាងក្រៅអត់?

ខ៖ ខ្ញុំអត់មានឈ្មោះហើយខាងក្រៅទេ ខ្ញុំមានឈ្មោះតែមួយហ្នឹង។

ក៖ ឈ្មោះតែមួយហ្នឹងទេ?

ខ៖ ចា៎!

ក៖ ហើយតាំងពីក្មេងមកគេអត់មានហៅ ដាក់ងារអ្វីផ្សេងទេ?

ខ៖ អត់ទេ!

ក៖ ចា៎! មកដល់ឥឡូវអ្នកមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំ ៥៦ ហើយ។

ក៖ ៥៦! តើអ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ ខ្ញុំមានបងប្អូន១២នាក់។

ក៖ ១២នាក់ ហ្វ៎ច្រើនដែរ។ ១២នាក់ស្រីប៉ុន្មានប្រុសប៉ុន្មានដែរអ្នកមីង?

ខ៖ ស្រី៥ប្រុស៥នាក់។

ក៖ គាត់មានឈ្មោះអ្វីខ្លះទៅអ្នកមីង?

ខ៖ គាត់ហេ៎?

ក៖ ចា៎!

ខ៖ បងខ្ញុំបំផុតឈ្មោះជា។

ក៖ ចា៎!

ខ៖ មួយទៀតអញ្ចឹងទៅឈ្មោះនៅ ឈ្មោះនឹម
ហើយនិងឈ្មោះបងខ្ញុំដែលស្លាប់ទៅម៉ែខ្ញុំគាត់និយាយថាឈ្មោះផាត ឈ្មោះចាន់
អញ្ចឹងទៅណា៎។

ក៖ ចា៎!

ខ៖ បានមកខ្ញុំហើយខ្ញុំទៀតអញ្ចឹងទៅឈ្មោះកុយ ឈ្មោះញ៉រ ឈ្មោះច្រើនណាស់ដែរបងប្អូនរបស់ខ្ញុំវា១២នាក់ឯណោះណា៎។

ក៖ ចា៎!

ខ៖ ហ្នឹងហើយ!

ក៖ ប៉ុន្តែសព្វថ្ងៃនៅរស់ប៉ុន្មាននាក់ណាអ្នកមីង?

ខ៖ សព្វថ្ងៃនៅរស់តែ៤នាក់ទេ។

ក៖ ហ្អ៎តែ៤នាក់ទេ។

ខ៖ តែ៤នាក់ទេ ពីព្រោះអីតាំងពីយើងពីអាពតហ្នឹង គេយកទៅវៃចោលខ្លះហើយដល់ពេលយើងទៅធ្វើពលករ និងវិវត្តខ្លះអញ្ចឹងទៅណា៎។ តាំងពីជំនាន់ហ្នឹងណា៎តាំងពីជំនាន់ ៨៤(១៩៨៤) ៨៥(១៩៨៥) គេយកពលករ។

ក៖ គេយកទៅឯណាអ្នកមីង?

ខ៖ គេយកពលករថាយកទៅពេជ្រនិលពេជ្រអីអញ្ចឹងទៅ។ កាលពីជំនាន់នោះ។

ក៖ ចា៎!

ខ៖ ចា៎!

ក៖ គេយកទៅបាត់ដំណឹង១ចឹងទៅ?

ខ៖ យប់ទៅអញ្ចឹងទៅវាលបាត់អញ្ចឹងទៅណា៎។

ក៖ ហ្អ៎! អត់មានឃើញត្រឡប់មកវិញ?

ខ៖ ថាទៅកាប់ព្រៃហ្នឹង ហើយថាទៅកាប់ព្រៃកាប់អ្វីហ្នឹងណា៎។

ក៖ យើងអត់មានដឹងថាគាត់រស់ ឬក៏គាត់ស្លាប់អីទេ ដឹងតែបាត់ឈឹងទៅតែម្តងអ្នកមីង?

ខ៖ ហ្នឹងហើយ! ជំនាន់ហ្នឹងមក។

ក៖ អ្នកមីងកាលពីជំនាន់ប៉ុលពតអ្នកមានអាយុប៉ុន្មានដែរ?

ខ៖ ខ្ញុំកាលពេលជំនាន់ពលពតខ្ញុំអាយុ១៨ឆ្នាំ។

កៈ ចា៎! ១៧ឆ្នាំ! អ្នកមីងធ្វើអ្វីខ្លះនៅពេលជំនាន់ហ្នឹង?

ខៈ ខ្ញុំជំនាន់អាពត ខ្ញុំគេឱ្យខ្ញុំលើកទំនប់និងប្រពន្ធ័ភ្លឺស្រែ ច្រូតស្រូវហ្នឹងហើយជំនាន់ប៉ុល ពត ណា៎ ដូចទៅឱ្យគេឱ្យខ្ញុំទៅកាន់ភូមិឃុំគេថាពុកខ្ញុំឱ្យខ្ញុំទៅកម្លាំងស្រួចអញ្ចឹងទៅ។ គេឱ្យខ្ញុំទៅតាមឃុំវាឱ្យខ្ញុំទៅសៀមរាបទៅរៀនថ្មី ត្រូវស្រុកក្រសាំងអញ្ចឹងទៅឱ្យខ្ញុំរែកទំនប់ទៅតាមហ្នឹង អញ្ចឹងទៅ ព្រោះខ្ញុំកងកម្លាំងកងស្រួច។ គេហៅថាកុមារកងស្រួចរបស់គេនោះណា៎។ ហ្នឹងហើយការពេលជំនាន់ហ្នឹងហើយ ខ្ញុំកាលហ្នឹងពេលជាងមុន ប៉ុល ពត ក៏មានបាយមានទឹក ឯណាហូបទេគេចែកបបរ បបរមួយចាន បបរមួយចានលាយជាមួយពោតលាយដំឡូង បបរលាយគល់ចេកអញ្ចឹងទៅណា៎។ កាលពេលជំនាន់ហ្នឹងណា៎ អត់មានអ្វីហូបទេ កាលពីជំនាន់ ប៉ុលពតហ្នឹងនោះ វេទនាណាស់គិតថាមិនរស់ផងទេ កាលពេលហ្នឹង។

កៈ អ្នកមីងអត់មានឈឺអត់មានអីទេពេលហ្នឹង?

ខៈ ខ្ញុំឈឺដែរ។

កៈ អ្នកមីងឈឺ។

ខៈ ចា៎! ជំនាន់ប៉ុលពតហ្នឹងហើយហើមដោយសារយើងអត់មានអំបិលអត់មានអីហូបអញ្ចឹងទៅណា៎។ ហ្នឹងហើយយើងហូបតែបន្លែអីទៅទេអញ្ចឹងទៅយកមកលាយទៅវាហើយដែលកាលពីជំនាន់ប៉ុលពតហ្នឹង។

កៈ ចា៎!

ខៈ ហ្នឹងហើយ។

កៈ ហើយធ្វើយ៉ាងម៉េចបានស្រកអ្នកមីង?

ខៈ យើងចេះតែដើរហូបនេះហូបនោះយើងចេះតែឃ្លានទៅណា៎យូរៗទៅវាចេះតែជាឯងទៅណា៎។

កៈ ចា៎!

ខៈ ហ្នឹងហើយហើយដល់ពេលខ្ញុំទៅលើកទំនប់នៅស្រុកក្រសាំងវាអត់អីឃ្លានអីស៊ីអីពេក អញ្ចឹងទៅ កាលពេលជំនាន់ហ្នឹងវាមានពុល វាមានពុលណា៎។ កាលពេលជំនាន់ហ្នឹង វា

៧៧(១៩៧៧) ជំនាន់ឆ្នាំ ១៩៧៧ ណាំ។ ខ្ញុំកំពុងកងនារីនៅឆ្នាំ ៧៧ ឬ ៧៨ អីហ្នឹងណាំ។កាលពេលពុលហ្នឹង អាគេកំអួតគេនោះនៅហ្នឹងបង្គិខ្ញុំស្មានតែបាយក្រៀមដល់ពេលបែកក្រៀមហ៊ីយើងមកពីធ្វើការអញ្ចឹង វែកទំនប់ហ្នឹងឃើញបាយក្រៀមក៏ហៅគេពួកខ្ញុំដែលនៅជាមួយគ្នាហ្នឹងកងនារីហ្នឹងហៅមកថា ហូបបាយក្រៀមនេះណាំ ហ្អែងមើលឆ្ងាញ់ណាស់។ ចេះតែហូបមួបមួបពុលជំនាន់ហ្នឹង! ដល់ពុលពួកគ្នាខ្ញុំក៏ថា ហេសុីណា ដូចជាពុលហើយ ពុលស្អីគេ? ពេលដែលពេលកងនារីវគ្គពេលមុនលើកទំនប់ទប់ប្រឡាយហ្នឹង គេក្អួតពុលបាយ។ ឥឡូវវាសុីពុលបាយហ្នឹងវាក្អួត ដល់តែក្អួតគេថាខ្ញុំក្អួតហ្នឹង គេយកខ្ញុំឱ្យហូបស្ករហ្នឹងហើយ ក៏បាត់ទៅជំនាន់ហ្នឹងណាំ។

ក៖ ហូបស្ករបាត់?

ខ៖ ហូបស្ករបាត់ស្ករក្រហម យើងស្ករត្នោតហ្នឹងណាំ ក៏បាត់ទៅ។ កាលពីជំនាន់ប៉ុលពតខ្ញុំពិបាកវេទនាណាស់ កាលពេលជំនាន់ហ្នឹងនោះខ្ញុំនឹកឃើញថាខ្ញុំរស់បានដល់សព្វថ្ងៃនេះណាំ មួយទៅគេឲ្យយើងវែកទំនប់ទប់ប្រឡាយ ប៉ុន្តែគេមិនឱ្យបាយយើងហូបឯណា។ គ្មានអ្វីហូបគ្រប់គ្រាន់ ការពេលជំនាន់ហ្នឹងមានតែបបរព្រលិត បបរត្រកួនហ្នឹង ឲ្យយើងហូបបបរពោត អញ្ចឹងទៅគេឱ្យចែកយើងមួយកូនចានមួយកូនចានមួយនាក់ទេណាំ ១កូនចានម្នាក់ កាលពីជំនាន់ប៉ុលពតហ្នឹងអូនណាំ។

ក៖ ចាំ!

ខ៖ ហើយទំនប់ហ្នឹងខ្ញុំជាអ្នកលើកដែរ កើតពេលជំនាន់ហ្នឹងហ៎។

ក៖ ចាំ!

ខ៖ ដល់តែលើក ហើយនៅពេលហ្នឹង ខ្ញុំមើលគោមើលអីនៅទួលតាម៉កយើងនេះហ្នឹង។

ក៖ ចាំ!

ខ៖ ចាំ! ហ្នឹងហើយធ្វើនៅទីហ្នឹងតើខ្ញុំ។

ក៖ កាលពេលជំនាន់ប៉ុលពតក៏នៅទីហ្នឹងដែរអ្នកមីង?

ខ៖ ចាំ! ជំនាន់ប៉ុលពតក៏ខ្ញុំនៅទីហ្នឹង។

ក៖ អត់មានពេលជម្លៀសទៅទីណា?

ខ៖ គេជម្លៀសទៅដែរ។ ចម្រៀងទៅស្រុកស្រែរយោងជម្លៀសទៅគ្រប់តែភូមិហ្នឹង ទៅស្រែរយោង ទៅវត្តអង្គគ្រប់កន្លែងហ្នឹង ពួកខ្ញុំហ្នឹងហើយ។

ក៖ ហើយទៅដល់គេឲ្យវិលមកវិញ?

ខ៖ ឲ្យវិលមកវិញ។

ក៖ ហ៊ី! បានវិលមកស្រុកកំណើតវិញ។

ខ៖ ចាំ!

ក៖ កាលពេលនៅហ្នឹងបងប្អូនរបស់អ្នកមីងនៅជុំគ្នាទាំងអស់?

ខ៖ នៅជុំគ្នាបងប្អូននៅឯស្រុក ទូលតាម៉កហ្នឹងច្រើន។

ក៖ ដូចថាបងប្អូនអ្នកមីងបង្កើតអីហ្នឹង អត់មានគេជម្លៀសបែកទៅផ្សេងៗទេ?

ខ៖ គេជម្លៀសបែកផ្សេងៗអស់ហើយ ខ្លះទៅពោធិ៍សាត់ ខ្លះទៅបាត់ដំបង ខ្លះគេទៅនៅស្អាង អញ្ចឹងទៅណាំ ខ្លះគេទៅនៅស្អីគេណាបងខ្ញុំថានៅ បើបងរបស់ខ្ញុំមួយទៀតនៅដល់កោះគរ។

ក៖ ចាំ!

ខ៖ ហ្នឹងហើយ។

ក៖ ហើយគេទៅ ទៅបាត់រហូតឬក៏បានមកវិញខ្លះអ្នកមីង?

ខ៖ អ្នកខ្លះទៅបានមកវិញ អ្នកខ្លះទៅបាត់សូន្យទាំងអស់។

ក៖ ហ្ហ៎!

ខ៖ មួយក្រុម មួយក្រុមគ្រួសារអ្នកខ្លះបាត់ទៅ៣ ទៅ៤ គ្រួសារណាំ។

ក៖ ចាំ!

ខ៖ អាខ្លះគេថាទៅតាកៃរទៅទៅបាត់ដែរ ហើយអត់មានបានមកវិញទេ ហ្នឹងហើយម៉ែរបស់ខ្ញុំនិយាយណា៎ គាត់ថាបងប្អូនរបស់គាត់បាត់២ ទៅ៣ សំបុកអញ្ចឹងទៅណាដែលអត់បានវិលមកវិញណា៎។

ក៖ ចា៎!

ខ៖ ងាប់ពេលជំនាន់ប៉ុលពត។

ក៖ ចា៎!

ខ៖ ហ្នឹងហើយ។

ក៖ ចុះបងប្អូនរបស់អ្នកមីងអត់មានទៅប្រទេសក្រៅអីទេអ្នកមីង?

ខ៖ បងប្អូនខ្ញុំហោ៎។

ក៖ ចា៎!

ខ៖ អត់មានទៅប្រទេសក្រៅទេ។

ក៖ នៅតែស្រុកខ្មែរទាំងអស់?

ខ៖ នៅតែស្រុកខ្មែរហ្នឹងហើយ។

ក៖ អ្នកមីងធ្លាប់បានដើរទៅលេងខេត្តណាផ្សេងខ្លះអត់?

ខ៖ ខ្ញុំហោ៎?

ក៖ ចា៎!

ខ៖ ខ្ញុំកាលពេលចូលអង្គការបានទៅលេងខេត្តទៅបានខេត្តស្អីគេទេ ខ្ញុំភ្លេចហើយ ហ្ហ៎អង្គរវត្តម្តងដែរ។ កាលពេលខ្ញុំចូលអង្គការណា៎។

ក៖ អង្គការអីគេដែរអ្នកមីង?

ខ៖ អាហ្នឹងគេហៅអង្គការខាងស្អីគេភ្លេចបាត់ហើយខ្ញុំ អង្គការដើមត្នោត កូនរបស់ខ្ញុំនៅទីហ្នឹងទាំងអស់នោះអង្គការនៅអំពៅព្រៃនេះ។

ក៖ យូរនៅអ្នកមីង?

ខ៖ យូរហើយ៥ឆ្នាំ ៦ឆ្នាំហើយតាំងពីពេលខ្ញុំអាយុ៥១ឆ្នាំ។ ឥឡូវខ្ញុំ៥៦ហើយ។

ក៖ចាំ!

ខ៖ ហ្នឹងហើយ!

ក៖ ហើយគេចេះយកយើងទៅដើរលេងដែរ?

ខ៖ ចាំ! គេយកយើងទៅដើរលេងដែរ។

ក៖ សំណាងបានស្គាល់ខ្លះ។

ខ៖ សំណាងបានស្គាល់ពេលមុនខ្ញុំមិនដែលស្គាល់ទេ តែភ្នំពេញខ្ញុំមិនដែលស្គាល់ផង។

ក៖ហ្ហ៎!

ខ៖ ហ្នឹងហើយ! នៅពេលដែលខ្ញុំចូលអង្គការ អង្គការនាំខ្ញុំដើរលេងឲ្យបានស្គាល់ណា៎។ កុំអីអត់ដែលស្គាល់ទេមើលទៅ។

ក៖ ហើយចុះសមុទ្រអីអត់ដែលស្គាល់ទេអ្នកមីង?

ខ៖ អត់ដែលស្គាល់ទេខ្ញុំ។

ក៖ ហ៊ឺ! ស្តាយណាស់អ្នកមីង។

ខ៖ ផ្ទាល់តែម្តងខ្ញុំហ្នឹង ស្គាល់តែអង្គរវត្តដែលអង្គការនាំទៅហ្នឹង។

ក៖ ចាំសៗ!

ខ៖ ហ្នឹងហើយ!

ក៖ អ្នកមីងកាលពេលនៅក្មេងមានដែលលេងអ្វីជាមួយបងប្អូនរបស់មីងដែលអត់?

ខ៖ អត់ដែលមាន។

ក៖ អត់ដែលមាន?

ខ៖ កាលពេលជំនាន់ហ្នឹងខ្ញុំអត់មានទេពួកខ្ញុំ។

ក៖ អត់ដែលលេងជាមួយគ្នា?

ខ៖ ចាំ! អត់ដែលលេងជាមួយគ្នាអីហ្នឹងហើយ។

ក៖ ចាំ!

ខ៖ ហ្នឹងហើយ។

ក៖ ដូចថាលេងឈូស លេងគប់រង់លេងស្អី។

ខ៖ អត់ទេ! ខ្ញុំមានតែធ្វើការធ្វើងារតែម្តងពុកខ្ញុំហ្នឹងហើយ។

ក៖ ធ្វើការតែម្តង។

ខ៖ ធ្វើការតែម្តង។ កាលពេល៧៩ (១៩៧៩) យើងធ្វើការស្ទូងស្រូវតែម្តង ហើយយើងមិនទៅដាំពោតដាំអីដាំសណ្តែកអីជាមួយឪពុកម្តាយយើងអញ្ចឹង មានអ្នកណាគេលេងជំនាន់ហ្នឹង ជំនាន់ថ្មីឥឡូវបានដើរលេងសប្បាយហួរហៀវណាស់។

ក៖ ចាំស!

ខ៖ ស្លៀកពាក់អីអត់មានស្លៀកពាក់អីណាទេនេះទេ ក្មេងឥឡូវវាបានស្លៀកពាក់ហ៊ឺហាដោយសារវាសម្បុរបែបកាលពេលជំនាន់ខ្ញុំសំពត់ប៉ះអាវប៉ះដាក់ខ្លួនឯងទៀតទេ ខ្លួនឯងហើយសូម្បីតែរៀនហ្នឹងក៏មានខោអាវតែមួយកំប្លេដែរ។ មកពីរៀនវិញយើងគក់ខោអាវទុកអស់ហើយមិនមែនដូចក្មេងឥឡូវទេដែលឮសូរម្តាយរបស់ឯងនិយាយអត់? ដែរទេ?

ក៖ ដូចអត់សូវដែលឮ។

ខ៖ ហ៊ឺ! ជំនាន់ហ្នឹងសុទ្ធតែខោអាវប៉ាក់ហើយ។

ក៖ គាត់ធ្លាប់តែនិយាយរឿងជំនាន់ ប៉ុលពតប្រាប់។

ខ៖ ចាំស! ជំនាន់ប៉ុលពតក៏មានអាវប៉ះ ពេលយើង ៧៩ (១៩៧៩) ក៏មានអាចប៉ះដែរ។

ក៖ គាត់អត់ដែលប្រាប់ដែរ។

ខ៖ ខោអាវប៉ាក់ខោស្លៀកពាក់យើងហ្នឹងថារឿងថាមានរបស់របរអីស្លៀកពាក់ស្អាតបាតទេ ហ្នឹងហើយ។ ជំនាន់ហ្នឹងមកហើយនោះ។

ក៖ ចាំស!

ខ៖ ហ្នឹងហើយ!

ក៖ ហើយអ្នកមីងកាលពេលជំនាន់ប៉ុលពតអ្នកមានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំអាយុ ១៨ ឆ្នាំ។

ក៖ ហ្ហ៎! អ្នកមីង១៧ហើយ អ្នកមីងមានមិត្តភ័ក្រជិតស្និទ្ធដែរឬក៏អត់អ្នកមីង?

ខ៖ ខ្ញុំហេ៎?

ក៖ ចា៎! អ្នកមីងអត់ដែលមានមិត្តភក្តិដើរលេងជាមួយគ្នាទេណោះ?

ខ៖ អត់ទេខ្ញុំ។

ក៖ ហើយនៅដូចថានៅក្មេងៗក៏អត់មានមិត្តភ័ក្រជិតស្និទ្ធអីដែរអ្នកមីងណោះ?

ខ៖ អត់ទេ។ ហ្នឹងហើយស្រែករពួកខ្ញុំអត់មានមិត្តភ័ក្រទេហ្នឹងហើយ។

ក៖ ហើយ!

ខ៖ តែទៅរៀន ទៅរៀនហើយមកដល់ផ្ទះវិញហូបបាយធ្វើការធ្វើងារហើយ។

ក៖ ចា៎ស! អ្នកមីងតាំងពីក្មេងមកអ្នកមានធ្វើអីគេទៅ?

ខ៖ ខ្ញុំហេ៎?

ក៖ ចា៎!

ខ៖ ខ្ញុំតាំងពីក្មេងមកនៅជាមួយម៉ែខ្ញុំ ខ្ញុំដាំត្រកួនលក់ម្ដាយឪពុករបស់ខ្ញុំ រកត្រីខ្ញុំលក់ត្រីជាមួយម៉ែខ្ញុំអញ្ចឹងទៅ។ កាលពេលជំនាន់៧៥ (១៩៧៥) ណា៎ហ្នឹងហើយចំនួន៧៥គ្រាប់ផ្លោង ហើយហ្នឹងណា៎ ជំនាន់គ្រាប់ផ្លោងហើយ ពិបាកវេទនាតែពេលដេកក៏យើងពិបាកដែរ គ្រាប់ផ្លោងមកយើងចូលក្នុងត្រង់សេឃើញទេ កាលពីជំនាន់៧៥ដល់ពេលអាពតក៏អញ្ចឹងទៀត ពេលយើងអត់មានបាយហូបគ្រប់គ្រាន់ទេ ជំនាន់ប៉ុលពតណា៎។

ក៖ ចា៎!

ខ៖ ខ្ញុំបានអីហូបគ្រប់គ្រាន់បើវាឱ្យយើងធ្វើការ ហើយស្រូវអីធ្វើបានអីបាន ប៉ុន្តែវាអាចឱ្យស៊ីយើងស៊ីទេ។

ក៖ ចា៎!

ខ៖ កាលពេលជំនាន់ប៉ុលពតហ្នឹងហើយ! បបរដំឡូងឱ្យយើងចែកគ្នាបបរពោតឱ្យយើងចែកគ្នាស៊ី កាលពីជំនាន់ប៉ុលពតមកហើយឱ្យរែកទំនប់ទប់ប្រឡាយយើងវាហាត់ ការងារម្នាក់ៗថាយើងម្នាក់ៗខ្លះក៏អស់ជីវិតអញ្ចឹងទៅ ខ្លះនៅមានជីវិតអញ្ចឹងទៅ។ កាលពីជំនាន់ប៉ុលពតណា៎។ ក៖ ចា៎ស!

ខ៖ ខ្លះគេយកទៅសម្លាប់ចោលទៅ យកទាំងគ្រួសារទាំងគ្រួសារជំនាន់ប៉ុលពត ប៉ុន្តែពួកខ្ញុំឱ្យតែឮស្ងួរសេះមកកុបៗមកហ្នឹង ពួកម៉ែឪខ្ញុំសុទ្ធតែដំបងត្រៀមអស់ហើយ ដើម្បីឱ្យជៀសវាងផុតតែយើងកុំឱ្យដូចក្រុមគ្រួសាររ៉ៃយើងទៀត ដល់អញ្ចឹងទៅណា៎។

ក៖ ចា៎!

ខ៖ ពួកហ្នឹងចេះតែជាផុតៗទៅហ្នឹង។

ក៖ ចេះសំណាង។

ខ៖ ដល់ពេលជំនាន់ ៧៧ (១៩៧៧) បងប្អូនរបស់ខ្ញុំប្រុសបីនាក់ដែរបងប្អូនរបស់ខ្ញុំប្រុសៗណា៎។

ក៖ ចា៎ស!

ខ៖ គេយកទៅ គេថាយកទៅឲ្យទៅថាជីកប្រឡាយទៅជាប្រឡាយថាអញ្ចឹងថាទៅជីកប្រឡាយ អញ្ចឹងទៅក៏បាត់រហូតដល់សព្វថ្ងៃហ្នឹងទៅ។ បងប្អូនរបស់ខ្ញុំប្រុសៗណា៎៣នាក់ហ្នឹងហើយបងប្អូនជីដូនមួយ ជីដូនមួយខ្ញុំទៀតក៏ច្រើនដែរ។ កាលពីជំនាន់ប៉ុលពតហ្នឹង។

ក៖ ហើយចុះអ្នកវិញអត់ដឹងថាបងប្រុសរបស់អ្នកនាងគាត់ស្លាប់ឬក៏រស់អីទេណោះ?

ខ៖ គាត់ស្លាប់អស់ហើយគេទៅវ៉ៃចោលអស់ហើយ កាលពីជំនាន់ប៉ុលពតហ្នឹង។

ក៖ យកអស់ទៅតែម្តង?

ខ៖ យកទៅអស់។

ក៖ ដឹងថាយើងបាត់ដំណឹងឈឹងរឺក៏ដឹងថាវ៉ៃដែរ?

ខ៖ គេដឹងថាយកទៅទន្លេបាទីវ៉ៃចោលអស់ហើយ បងប្អូនរបស់ខ្ញុំហ្នឹងជំនាន់ ប៉ុល ពត ហ្នឹង។

ក៖ ហ្ន៎! ដឹងដែរ។

ខ៖ ចាំសដឹងដែរ ពីព្រោះពេលអ្នកយកបងរបស់ខ្ញុំយកទៅវ៉ៃចោល
និងដល់ពេលទៅគេមកប្រាប់គេមកនិយាយវិញណាំ ហ្នឹងហើយ
គេកំពុងតែនិយាយគ្នាថាបងប្អូនពួកកូនតាសេនហ្នឹងគេយកវ៉ៃចោលអស់ហើយប្រុសៗ
ដែលយកទៅរែកដី ប៉ុន្តែអត់មានលេខដីទេយកទៅវ៉ៃចោលនៅទន្លេបាទីអស់ហើយ។

ក៖ អត់មានបានធ្វើខុសអ្វីទេអ្នកមីង?

ខ៖ អត់មានបានធ្វើខុសទេបងប្អូនខ្ញុំនឹងនោះគេយកទៅវ៉ៃចោលតែម្តង
កាលពីជំនាន់ប៉ុលពតហ្នឹង។

ក៖ ហើយម្តាយរបស់អ្នកមីងឈ្មោះអ្វីដែរ?

ខ៖ ម្តាយរបស់ខ្ញុំ ឈ្មោះឆាំ ហួយ ។

ក៖ គាត់អាយុប៉ុន្មានហើយអ្នកមីង?

ខ៖ ម៉ែរបស់ខ្ញុំអាយុ ៨៣ ឆ្នាំ។

ក៖ គាត់នៅរស់តែអ្នកមីង?

ខ៖ អត់ទេគាត់ស្លាប់បាត់ហើយ។

ក៖ គាត់ស្លាប់ដោយសារអីគេទៅអ្នកមីង?

ខ៖ គាត់ស្លាប់ដោយសារគាត់ឈឺ។

ក៖ ឈឺ!

ខ៖ ចាំស!

ក៖ ហើយចុះឪពុករបស់អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំក៏លើសឈាមស្លាប់ដែរ គាត់ស្លាប់លើឈាមដែរ។

ក៖ គាត់ស្លាប់អាយុប៉ុន្មានទៅអ្នកមីង?

ខ៖ ឪរបស់ខ្ញុំការស្លាប់អាយុ ៧៧ ឆ្នាំ។

ក៖ ៧៧ តិចដែរ។

ខ៖ ចាំ!

ក៖ គាត់ស្លាប់នៅឯណាទៅអ្នកមីង?

ខ៖ គាត់ស្លាប់នៅស្ទឹងជ្រៅការពេលខ្ញុំនៅទីហ្នឹង។

ក៖ កាលពីមុនអ្នកមីងនៅស្ទឹងជ្រៅ?

ខ៖ ចាំ! ខ្ញុំនៅស្ទឹងជ្រៅ។

ក៖ ហើយបានប្តូរមកនៅទីនេះវិញ?

ខ៖ ហើយបានប្តូរមកនៅទីនេះវិញហ្នឹងហើយ
កាលពេលប្តីរបស់ខ្ញុំធ្វើទាហានណាំប្តីរបស់ខ្ញុំគាត់ទៅធ្វើទាហាននៅឆ្នាំគេចាប់ទាហានច្រើន
នៅឆ្នាំ៨៥ (១៩៨៥) ៨៣ (១៩៨៣) ៨៥(១៩៨៥)ប្តីរបស់ខ្ញុំធ្វើទាហានហើយ។

ក៖ ទៅដល់ណាទៅអ្នកមីងណោះ?

ខ៖ ប្តីរបស់ខ្ញុំទៅធ្វើទាហាននៅកងពលខាងឯកសំអូន វារៈ ៩១នោះ។

ក៖ ខ្ញុំអត់សូវស្គាល់។

ខ៖ ឯងស្គាល់ទេការពេលជំនាន់ហ្នឹងមក ៨២ (១៩៨២) ៨៣(១៩៨៣)
យើងធ្វើទាហានហើយទាហានកងពលហ្នឹងណាំ ហ្នឹងហើយចាំ
បានគេផ្លាស់គាត់ទៅវារៈ៩១នេះវិញហិ។

ក៖ ចុះឥឡូវគាត់ធ្វើអ្វីវិញអីគេដែរអ្នកមីង?

ខ៖ នៅសព្វថ្ងៃគាត់គេរំសាយគាត់អស់ហើយ តាំងពីរំសាយគាត់តាំងពេលឆ្នាំ១៩៩៦
មករំសាយ ចាំ។

ក៖ ហើយចុះសព្វថ្ងៃគាត់ធ្វើអីគេ?

ខ៖ សព្វថ្ងៃគាត់រកត្រី។

ក៖ រកត្រី!

ខ៖ ហ្នឹងហើយ!

ក៖ សព្វថ្ងៃគាត់អាយុប៉ុន្មានហើយអ្នកមីង?

ខ៖ ប្ដីខ្ញុំអាយុ ៥៥ ឆ្នាំ។

ក៖ ចាស! ហើយអ្នកមីងមានកូនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ ខ្ញុំមានកូន ៩ នាក់។

ក៖ ៩ នាក់!

ខ៖ ចាស!

ក៖ ហើយពួកគាត់សុទ្ធតែមានគ្រួសារអស់ហើយឬក៏?

ខ៖ ពួកគាត់មានគ្រួសារ៤នាក់។ ហើយនៅរៀន ៥ នាក់។

ក៖ ចាស! បាននៅរៀនដែរអ្នកមីង?

ខ៖ ចាស!

ក៖ គាត់ធ្វើការងារអ្វីដែរអ្នកមីង?

ខ៖ កូនខ្ញុំមែនទេ?

ក៖ ហ្នឹងហើយ ដែលមានគ្រួសារហ្នឹង?

ខ៖ មានគ្រួសារធ្វើរកតែត្រី យើងមានមុខរបររកអ្វីរកតែត្រីហ្នឹងនៅទីនេះ។

ក៖ ចាស! អីលក់នៅផ្សារណាដែរ?

ខ៖ លក់នៅផ្សារព្រែកហូរ។

ក៖ ផ្សារព្រែកហូ!

ខ៖ ចាស!

ក៖ ពួកគាត់សុទ្ធតែប្រកបមុខរបរហ្នឹងតាំងពីយូរណាស់មកហើយ?

ខ៖ ចាស! ប្រកបយូរណាស់ហើយមុខរបររកត្រីហ្នឹង។

កៈ ចុះគ្រួសាររបស់អ្នកមីងកាលពីមុនគាត់ធ្លាប់រកត្រីដែរអ្នកមីងណោះ?

ខៈ កាលពេលមុនប្ដីរបស់ខ្ញុំធ្វើទាហាន។

កៈ ធ្វើទាហានទៀត។

ខៈ ចាំស! ដល់ពេលគេរំសាយអញ្ចឹងមកក៏ខ្ញុំនៅរកត្រីរកអីអញ្ចឹងទៅ
អត់មានមុខរបររកអីណាំ។

កៈ ចាំ!

ខៈ ហ្នឹងហើយ។

កៈ ចាំស! ឥឡូវហ្នឹងគាត់នៅទីហ្នឹងតើអ្នកមីងណោះ?

ខៈ ចាំស! នៅទីហ្នឹង។

កៈ អត់មានទៅ រកត្រីបាត់?

ខៈ
នៅទេអត់ទាន់ទៅរកទេព្រោះអីខេត្តនេះអត់ទាន់រកបានទេព្រោះអីទឹកអត់ទាន់ចូលដល់ពេលចូលទឹកឡើងទៅបានយើងរកបានណាំ។

កៈ ចាំស!

ខៈ
ដល់ពេលឥឡូវខ្ញុំដើរបេះត្រកួនដើរបេះត្រួយសារម៉ៅលក់អញ្ចឹងទៅផ្ញើអីអញ្ចឹងលក់តិចតួចទៅ។

កៈ ទៅរកដល់ណាអ្នកមីង?

ខៈ ខ្ញុំបេះក្រោយក្រោយហ្នឹងទៅ។

កៈ ក្រោយៗមានដែរ?

ខៈ ចាំស!
ជួនកាលខ្ញុំដើរទៅបេះដល់ក្របៅដល់អីអញ្ចឹងទៅតាមប្រឡាយតាមអីអញ្ចឹងទៅយើងចិញ្ចឹមចៅព្រោះអីចៅកំព្រា ៩នាក់ម៉ែវាលង់ទឹកស្លាប់ទៅ។

ក៖ ហ៎! កូនរបស់អ្នកមីងលង់ទឹកស្លាប់?

ខ៖ ចាំស! លង់ទឹកស្លាប់ទៅ កូនរបស់ខ្ញុំមីមួយទី២ហើយវាមានកូន ៤ នាក់នៅជាមួយខ្ញុំសព្វថ្ងៃហ្នឹង។

ក៖ ហ្អ៎! អាណិតណាស់។

ខ៖ មានស្រី២ ប្រុស២។

ក៖ ស្តាយណាស់ហើយកូននៅកំព្រា។

ខ៖ ចាំស នៅកំព្រា។

ក៖ ចុះឪពុករបស់គេ?

ខ៖ ឪពុករបស់គេ គេមានប្រពន្ធទៀត។

ក៖ ហ្អ៎! កុំទុកឱ្យម៉ាក់មើល។

ខ៖ ខ្ញុំមើលដល់សព្វថ្ងៃនេះ។

ក៖ អើយគឺយ៉ាប់ណាស់ ហើយកូនប៉ុន្មានទៅអ្នកមីង?

ខ៖ កូនអាបងវាអាយុ ១៤ ឆ្នាំបន្ទាប់មក១២ ឆ្នាំបន្ទាប់មកទៀត ៩ឆ្នាំអាមួយតូចនោះ ៧ឆ្នាំ។

ក៖ នៅក្មេងៗដែរ។

ខ៖ ចាំសនៅក្មេងៗដែរ។

ក៖ គាត់លង់ទឹកមាត់ស្លាប់អាយុប៉ុន្មានអ្នកមីង?

ខ៖ គាត់អាយុ ៣១ ឆ្នាំ។

ក៖ ៣១ ឆ្នាំអាយុដំណាលខ្ញុំ ឥឡូវហ្នឹងខ្ញុំ ៣១ ឆ្នាំហើយ។

ខ៖ ៣១! លង់ទឹកស្លាប់នៅខាងមុខនោះ
ដល់ពេលយើងអត់ខ្លាំងពេកទៅយើងទៅស៊ីឈ្នួលលក់ត្រីលក់អីឱ្យគេអញ្ចឹងទៅ
វាខ្យល់អញ្ចឹងទៅណា៎។ !ហ្នឹងហើយក៏លង់ទឹកស្លាប់តែម្តង
ទៅទៅលាងដៃលាងដៃខ្យល់ចាប់។

កៈ អ្នកមីងមិនស្គាល់ថ្ងៃខែឆ្នាំកំណើតរបស់ឪពុកម្តាយរបស់អ្នកមីងដែរឬក៏អត់?

ខៈ ឪពុកម្តាយខ្ញុំហ៎?

កៈ ចាស!

ខៈ ឪពុកម្តាយរបស់ខ្ញុំ ខ្ញុំអត់ស្គាល់ទេ អត់ដែលស្គាល់ទេគាត់អត់ដែរប្រាប់ផង។

កៈ ចុះក៏ធ្លាប់និយាយប្រាប់របស់គាត់នៅក្មេងៗប្រាប់អ្នកមីងដែរឬអត់?

ខៈ ធ្លាប់តើ! គាត់មិនដែលនិយាយប្រាប់ពីប្រវត្តិគាត់កាលពីនៅក្មេងៗទេ
គាត់និយាយថាពីគាត់នៅក្មេងៗមកគាត់ថាគាត់នៅរកត្រីរកអីនៅស្រុកកំណើតនៅភូមិនៅទឹក
ដីរបស់គាត់អញ្ចឹងទៅណាម៉ែឪខ្ញុំគាត់រកត្រីរកអីអញ្ចឹងដែរទៅណា៎។

កៈ ចាស!

ខៈ ហ្នឹងហើយគាត់ប្រាប់តែអញ្ចឹង។

កៈ គាត់អត់ដែលមានប្រាប់ ធ្លាប់ថាទៅទីណាទីណីអីទេ?

ខៈ អត់មានទៅទីណាទៅណីអីទេ តែគាត់ធ្លាប់ធ្វើទាហានធ្វើអ្វីកើតពេលជំនាន់ លន់ នល់
ខ្លួនឯងអញ្ចឹងពីសម័យតស្សូរអីអញ្ចឹងទៅណា៎។

កៈ ចាស!

ខៈ ការពេលហ្នឹងគាត់ទាហានអីអញ្ចឹងទៅ។

កៈ ចាស!

ខៈ ដៃយើងពីដើមសុទ្ធតែទាហានមែនណា៎
យើងមិនបានសុខសាន្តដូចជាយើងដេកស្រួលស្រួលដូចសម័យឥឡូវនេះទេ។
កាលពីជំនាន់ហ្នឹងមកហ្នឹងហើយ ធ្វើទាហានតែរហូតហ្នឹង។

កៈ ចាសចាប់ទាហាន យើងមិនទៅមិនបាន។

ខៈ យើងមិនទៅមិនបានទេហ្នឹងហើយ។

កៈ គឺត្រូវតែទៅ។។

ខ៖ ហ្នឹងហើយគាត់ប្រាប់កូនអញ្ចឹងដែរ។ នៅពេលហ្នឹងវាថាវាដៃបាក់ដៃវាជើងបាក់ជើងពីអាពតណាំយើញទេ។

ក៖ ចាំស!

ខ៖
គេឲ្យយើងទៅណាគេឱ្យខ្ញុំធ្វើអីយើងត្រូវតែធ្វើចឹងហ្នឹងហើយដល់អញ្ចឹងយើញយកយើងវ៉ៃចោលយើញទេអញ្ចឹង។ យើងធ្វើការងារយ៉ាងណាក៏វានៅតែវ៉ៃចោលដែរ។

ក៖ ចាំស!

ខ៖ ហ្នឹងហើយ!

ក៖ ចុះអ្នកមីងនៅក្នុងពេល មើលអាពតហ្នឹងអ្នកមីងធ្វើការងារអ្វីខ្លះទៅ?

ខ៖ ខ្ញុំនៅពីអាពត គេឱ្យខ្ញុំការទៅច្រូតស្រូវ
ខ្ញុំទៅច្រូតស្រូវបើឲ្យស្ទូងខ្ញុំទៅស្ទូងៗចឹងទៅវាមានតាមគេប្រើ អញ្ចឹងទៅណាំ។

ក៖ ចាំស!

ខ៖ ហ្នឹងហើយដូចថាវាឲ្យយើងទៅលេងទំនប់ទឹកប្រឡាយអញ្ចឹង
យើងទៅដេកទៅប្រព័ន្ធភ្លឺហ្នឹង ប្រព័ន្ធភ្លឺទៅ។

ក៖ ប្រព័ន្ធភ្លឺយ៉ាងម៉េចទៅអ្នកមីង?

ខ៖ ប្រពន្ធភ្លឺស្រែយើងប្រពន្ធភ្លឺស្រែ យើងគេឱ្យក្នុងថាចែកគ្នាមួយនាក់៥ម៉ែត្រ ឬក៏
៦ម៉ែត្រឲ្យយើងធ្វើប្រព័ន្ធភ្លឺមួយហ្នឹងឲ្យហើយ។
កាលណាយើងធ្វើប្រព័ន្ធភ្លឺមិនហើយគេឱ្យយើងស៊ីបាយទេ។

ក៖ ប្រព័ន្ធភ្លឺហ្នឹងដូចថាខ្ពស់?

ខ៖ លើកវាឱ្យខ្ពស់ហ្នឹងហើយដល់ពេលយើងស្ទូងស្រូវស្ទូងអីចឹងទៅណាំ
អាហ្នឹងប្រព័ន្ធភ្លឺស្រែដូចនៅក្នុងគេច្រៀងអញ្ចឹងទៅណាំ។

ក៖ មិនដែលឮ។

ខ៖ អាហ្នឹងនៅពីអាពតជាចម្រៀងនៅពេលអាពតវាច្រៀងអញ្ចឹងឲ្យយើងនោះ។

ក៖ ចាំស!

ខ៖ ហ្នឹងហើយជំនាន់កាលពេលអាពត។

ក៖ អ្នកមីងចេះច្រៀងដែរអ្នកមីង?

ខ៖ ខ្ញុំហ៎! កាលពេលអាពត ចុះច្រៀងខ្លះៗដែរ តែឥឡូវចាំដែរ។

ក៖ ចុះអ្នកមីងចង់ច្រៀងឥឡូវទេអ្នកមីង?

ខ៖ ចង់ច្រៀងឥឡូវក៏បាន។

ក៖ ច្រៀងមួយបទមកអ្នកមីង។

ខ៖ ពេលអាពតគេច្រៀងហើយគេធ្វើកាយវិកាដូចថាយើងទទូលក្បាលក្រមាអញ្ចឹងទៅ។
កាត់មួយចម្ការ កាប់មួយចម្ការ បង្កើនផលល្លាយកឲ្យកងទ័ព យើងខំកាប់គាស់ឱ្យបានរហ័ស
យើងខំកាប់គាស់ឲ្យបានរហ័ស ទ័ពយើងវាយឈ្នះពួកអាឃោរឃៅ។
ពួកយើងវាយឈ្នះចាប់ពួកក្បត់អាឃោរឃៅ សម្លបាយទូលម្លូបគ្រប់មុខ
សម្លបាយទូលម្លូបគ្រប់មុខ យកឲ្យកងទ័ពកូនចៅប្រជាជន យកឲ្យកងទ័ពកូនចៅប្រជាជន។
អាហ្នឹងបទពីអាពតណា៎។

ក៖ ចាំស! ហ្នូអ្នកមីងនៅចាំទៀត?

ខ៖ នៅចាំណា៎នៅចាំ។

ក៖ ហើយគេបង្រៀនអ្នកមីងនមែនទេ?

ខ៖ មានបង្រៀនឲ្យច្រៀង តើកុមារតាមក្រុមតាមក្រុមគេអញ្ចឹងយើងមិនច្រៀង។

ក៖ អូយយើងត្រូវតែឱ្យចេះតែម្តង។

ខ៖ គេឱ្យយើងច្រៀង យើងច្រៀងហើយ។ យើងជាកុមារស្រឡាញ់អង្គការអត់មានព្រំដែន
ដោយសារអង្គការយើងខ្ញុំរស់រានជីវិតថ្កុំថ្កើងរីករាយអស្ចារ្យ
មុនបដិវត្តន៍យើងកម្សត់រងទុក្ខវេទនា
ឥឡូវដោយសារអង្គការយើងខ្ញុំរស់រានជីវិតថ្កុំថ្កើងអង្គការបរវរ។ អាហ្នឹង
ពេលអាពតគេច្រៀងអញ្ចឹងទៀតថាបទគេច្រើនណាស់ពីអាពតនោះ។ បទពីអាពតតែអញ្ចឹង
យើងនៅតែត្រូវគេយកវ៉ៃចោលដដែល ហើយបើកវិញច្រៀងបទមួយទៀត

វាថាវាយកយើងហ្នឹងសម្លាប់ហើយវាច្រៀងបទហ្នឹងទៀត។
វាច្រៀងថាវាឱ្យយើងច្រៀងដូចថាយើងប្រព័ន្ធភ្លឺស្រែក្រឡាដើងត្រង់ៗចឹង
វាដាក់គំនាបឲ្យយើងច្រៀងអញ្ចឹងឃើញទេ។ អាហ្នឹងបទស្អីគេខ្ញុំភ្លេចហើយ
បទស្អីគេទេឱ្យយើងក្រឡាជើងត្រង់ប្រពន្ធភ្លឺស្រែ ក្រឡាឈើត្រង់បានល្អចង់បានត្រង់
១៣ណាំ។ ខ្ញុំអាហ្នឹងខ្ញុំភ្លេចដែរហើយ។

ក៖ ហ្នឹងហើយ។

ខ៖ នៅតែឱ្យយើងច្រៀងអាហ្នឹងដដែល
ហើយវាខ្វះអ្វីពេលអាពតចម្រៀងឱ្យយើងច្រៀងថាវាឱ្យយើងច្រៀង
យើងវាមិនច្រៀងម៉េចហ្នឹងកើត បើគេចងកុមារជាកងក្រងឲ្យគេច្រៀងៗចឹងហើយហ្នឹង
ហ្នឹងហើយៗ ហើយយើងមិនច្រៀងតាមបទរបស់វាម្ដេចនឹងកើត។ កាលពីជំនាន់ ប៉ុល ពត
ហ្នឹងហើយ ហើយខ្ញុំឲ្យស៊ីបបរចែកគ្នាហ្នឹង ជាមួយអង្គការ។
កាលពេលជំនាន់ហ្នឹងរាល់ថ្ងៃយើងពិបាកវេទនាដែរ។

ក៖ ចាំស! ហ្នឹងហើយ។

ខ៖ ហ្នឹងហើយ ហើយវាឱ្យយើងច្រៀងបទ
បទអ្វីក៏យើងច្រៀងបទអ្វីក៏យើងច្រៀងហ្នឹងហើយជំនាន់ហ្នឹងមក។

ក៖ អ្នកមីងរៀបការមុនប៉ុលពតហើយ?

ខ៖ ខ្ញុំការឆ្នាំ ៨២ (១៩៨២)។

ក៖ ៨២ (១៩៨២)!

ខ៖ ចាំស!

ក៖ ហ្ស! ទាល់តែបែកប៉ុលពតហើយ?

ខ៖ ចាំស! បែក ប៉ុល ពត ហើយបាន ៤ឆ្នាំ ៥ឆ្នាំដែរ។

ក៖ ហ្នឹងហើយ អ្នកមីងជួបគ្នាដោយសារឪពុកម្ដាយរៀបចំឲ្យឬក៏មិនជួបគ្នាដោយខ្លួនឯង
អញ្ចឹងណាំ?

ខ៖ ខ្ញុំជួបគ្នាដោយសារឪពុកម្ដាយរបស់ខ្ញុំ។

កៈ ឪពុកម្ដាយរៀបចំឱ្យ?

ខៈ ចាំស! ឪពុកម្ដាយរៀបចំឲ្យហ្នឹងហើយ។

កៈ មានជំនូនមានអ្វីទេពេលហ្នឹងជំនាន់ហ្នឹងអ្នកមីងណោះ?

ខៈពេលការហ្នឹងមែនទេ អត់មានចំនូនអត់មានអីទេអត់មានទេ។

កៈ ចាំស! អត់មានគេថាថ្លៃបណ្ណាការថ្លៃអីអត់ទេ?

ខៈ អត់ទេ គ្រាន់តែយើងយកបន្តិចបន្តួច កាលពីជំនាន់ហ្នឹងអាយុច្រើនបានទេ។

កៈ ចាំស!

ខៈ ហ្នឹងហើយ ១ជី ២ជី អញ្ចឹងទៅតាមជំនាន់។

កៈ ចាំស! ហើយមានការមានអីដូចយើង?

ខៈ ចាំស! ការអ្វីត្រឹមត្រូវតើ។

កៈ មានភ្លេងមានអីដូចយើងឥឡូវហ្នឹងដែរ?

ខៈ មានភ្លេងមានអ្វីទាំងអស់ មានអាសាស មានអីដូចយើងឥឡូវហ្នឹងអញ្ចឹង
កាលពេលជំនាន់ខ្ញុំហ្នឹងអកកេសមាន ៧០០ហើយ។

កៈ៖ ឡូយណាស់អ្នកមីង។

ខៈ កាលពេលជំនាន់ហ្នឹង ហ្នឹងហើយ។

កៈ តាំងពីជំនាន់ហ្នឹងមាន។

ខៈ មានគេធ្វើសក់មានគេធ្វើអីហើយណាំ ធ្វើសក់ឱ្យ ១២០។

កៈ អូ៎! មានធ្វើសក់ទៀត។

ខៈ មានធ្វើសក់មានធ្វើអីហើយ ហើយពេលអ៊ុំខ្ញុំការណ៍នេះហ្នឹង គេអត់មាននេះទេ
គេចងដៃស្រូវគេចងដៃអីទេណាំ។ កាលពីជំនាន់គាត់ការណាំ
មានបានអ្វីអត់បានធ្វើខ្លួនបានស្អាតបាតអត់មានម្សៅអត់មានអីទេ
ម្សៅអីចេះតែច្របាច់លាបធ្វើខ្លួនឲ្យបន្តិចបន្តួចទៅណាំ។ បើជំនាន់ខ្ញុំអាហ្នឹងបានមានមែន។

ក៖ ចាស!

ខ៖ មានគេធ្វើខ្លួនគេធ្វើអីហើយ ហើយចងដៃយើងជំនាន់ហ្នឹងលក់ ១០រៀល ៥រៀល ៧រៀលចាយលុយណាំ។

ក៖ ចាសៗ!

ខ៖ កាលពីជំនាន់ហ្នឹងអី។

ក៖ អ្នកមីងចាំថាអ្នកមីងការនៅថ្ងៃណាខែណាឆ្នាំណាអីទេ?

ខ៖ ខ្ញុំហេ៎?

ក៖ ចាស!

ខ៖ ខ្ញុំការនៅឆ្នាំ ១៩៨៣។

ក៖ ដូចថាអត់មានចាំតែចាំថ្ងៃអីទេអ្នកមីងណោះ?

ខ៖ ខ្ញុំហេ៎?

ក៖ ចាស!

ខ៖ អត់មានចាំខែចាំថ្ងៃទេ ព្រោះខ្ញុំកាលនៅខែពិសាខ ខ្ញុំចាំតែខែខ្មែរ។

ក៖ ចាស អ្នកមីងបានចូលរៀនដែរទៅតើអ្នកមីង?

ខ៖ បានចូលរៀនដែរ។

ក៖ រៀនបានថ្នាក់ទីប៉ុន្មានអ្នកមីង?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី៤។

ក៖ ទី៤!

ខ៖ ចាស!

ក៖ មកដល់ឥឡូវអ្នកមានចេះមើលអក្សរខ្មែរដែរឬទេ?

ខ៖ ខ្ញុំចេះមើលដែរ។

ក៖ ចេះអានចេះអីទាំងអស់?

ខ៖ ចេះអានចេះមើលអីទាំងអស់។

ក៖ ហ្ហ៎! ល្អណាស់អញ្ចឹង។

ខ៖ ហ្នឹងហើយ។

ក៖ ព្រោះអ្នកខ្លះជំនាន់មុនៗចឹងអត់បានចូលរៀនចូលអីអញ្ចឹងណា៎។

ខ៖ អត់បានចូលរៀន ប៉ុន្តែខ្ញុំបានចូលរៀនថ្នាក់ទី៤ដែរ។

ក៖ ហើយអ្នកមីងចេះអ្វីភាសាផ្សេងក្រៅពីភាសាខ្មែរអត់?

ខ៖ អត់ចេះទេ កាលពីជំនាន់ហ្នឹងនោះ កាលពេលហ្នឹងគេអត់ឱ្យរៀន
តែយើងមានគេចាប់សូម្បីតែចាក់បទចម្រៀងយើងពីដើមគេឲ្យចាក់ផង។
ពេលជំនាន់ហ្នឹងមកណា៎ សូម្បីតែយើងរៀនគេសុទ្ធតែចាប់គ្រូតែម្តង
អ្នកណារៀនគឺចាប់ហើយរៀនអង់គ្លេសរៀនបារាំង។
កាលពេលហ្នឹងយើងរៀនបារាំងមិនមែនរៀនអង់គ្លេសទេណា៎។

ក៖ ចា៎ស!

ខ៖ មានតែបារាំង កាលហ្នឹងរៀនតែបារាំងទេ។ កាលពេលជំនាន់ហ្នឹងមក អត់មានរៀនទេ
ព្រោះតែយើងរៀនគេចាប់យើងអត់ឱ្យរៀន។

ក៖ ចា៎ស!

ខ៖ កាលពេលជំនាន់ហ្នឹងតឹងតែងណាស់ អើរយើងកុម្មុយនិស្តវាត្រឹមត្រូវហើយ
កាលពីជំនាន់ហ្នឹងមកហ្នឹងហើយ។

ក៖ សម័យរដ្ឋកម្ពុជា។

ខ៖ រដ្ឋកម្ពុជាកុម្មុយនិស្តហើយអត់ឱ្យមានយើងរៀនផង។
កាលពីជំនាន់រដ្ឋកម្ពុជាត្រូវហើយរដ្ឋកម្ពុជាជំនាន់ហេងសំរិន ។

ក៖ ប៉ុល ពត ហើយឬក៏មុនពលពតអ្នកមីង?

ខ៖ អាហ្នឹង ប៉ុល ពត ហើយ។

ក៖ ប៉ុល ពត ហើយ?

ខ៖ ចាំស!

ក៖ ប៉ុល ពត ហើយនៅតែអត់ឱ្យរៀនទៀត?

ខ៖ ប៉ុល ពត ហ្នឹង គេឱ្យរៀនហើយ ប៉ុន្តែបើយើងរៀនភាសាគេអត់ឱ្យរៀន។

ក៖ ហ្ហ៎! ឱ្យរៀនភាសាទេ?

ខ៖ ចាំស! រៀនតែភាសាខ្មែរទេ។

ក៖ ចាំស!

ខ៖ បារាំងគេឱ្យរៀនទេហ្នឹង ហើយតាំងពីជំនាន់ហ្នឹងមក។

ក៖ ចាំស!

ខ៖ ម៉ូតូ ក៏អត់ឲ្យយើងជិះដែរឲ្យជិះតែកង់។

ក៖ ម៉ូតូទៀត?

ខ៖ ហ្នឹងហើយ។

ក៖ ឱ្យជិះកង់ ប៉ុន្តែមកពីអត់មានម៉ូតូទេអ្នកមីង?

គ៖ ប៉ុន្តែខ្ញុំមានម៉ូតូគេ អត់អោយជិះគេចាប់!!!

ក៖ ហ្ហ៎!

ខ៖ ជំនាន់ហ្នឹងតឹងតែងណាស់អូនអើយ។

ក៖ ចាំស! ចុះអ្នកមីងដែលធ្លាប់ឆ្លងកាត់ខ្ញុំឮគេហៅថាក៥អីនោះ?

ខ៖ ក៥ហ្នឹងហើយ ជំនាន់ក៥បងរបស់ខ្ញុំអីហ្នឹងទៅហ្នឹង។

គ៖ ពលករ ក៥ ហ្នឹងហើយ។

ខ៖ ក5 និង ពលករហ្នឹងហើយ។

ក៖ ចាំស!

ខ៖ ខ្ញុំអត់បានទៅទេ ប៉ុន្តែបងខ្ញុំបានទៅ។

ក៖ យ៉ាងម៉េចបានគេឲ្យទៅអ្នកមីងណោះ?

ខ៖ ខ្ញុំអត់ដឹងដែរ ថាផែនការរបស់អង្គការគេ គេឱ្យថាទៅកាប់ព្រៃអញ្ចឹងតែម្ដង កាប់ព្រៃទាំងស្រីទាំងប្រុស អាខ្លះមកចេញមកងាប់ច្រើនខ្លាំងណាស់។ កាលពីជំនាន់ហ្នឹងណាំ។

ក៖ យ៉ាងម៉េចបានគេមានចាញ់អញ្ចឹងអ្នកមីងណោះ?

ខ៖ ចាញ់។

ក៖ ដោយសារស្អីគេទៅ?

ខ៖ ចុះបើយើងទៅព្រៃភ្នំអញ្ចឹងយើងមិនចាញ់។

ក៖ ហ្អ!

ខ៖ យើងមានដែលទៅឯណាទឹកដីប៉ៃលិនទឹកដីអីគេកាប់ហ្នឹង។

ក៖ ចាំស!

ខ៖ ចាំស! ជំនាន់ហ្នឹងចាញ់ងាប់មកច្រើនណាស់។

ក៖ បើសិនជាទៅឥឡូវខ្ញុំគិតថាអត់មានចាញ់ទៀតទេ?

ខ៖ បើទៅឥឡូវគឺអត់ចាញ់ទេ។

ក៖ ចុះហេតុអ្វីបានជាវាផ្លាស់ប្ដូរអញ្ចឹងអ្នកមីង?

ខ៖ វាផ្លាស់ប្ដូរៗចឹងអត់ដឹងដែរ។

ក៖ ពីមុនមានអ្នកចាញ់ដល់ឥឡូវអត់ចាញ់។

ខ៖ ឥឡូវអត់ចាញ់។

ក៖ ចម្លែកណាស់អ្នកមីងណោះ?

ខ៖ ចម្លែកណាស់។ ចាំ!

ក៖ ដូចរឿងមួយហ្នឹងគួរឲ្យឆ្ងល់ដូចជាអាថ៌កំបាំងកន្លែងមួយដល់ហើយ។ ចុះអ្នកវិញដូចថាឥឡូវអ្នកមាននៅតែចូលចិត្តចម្រៀងដែរតើអ្នកមីងណោះ?

ខ៖ ឥឡូវខ្ញុំចូលចិត្តចម្រៀងដែរ។

ក៖ ចាំស!

ខ៖ ហ្នឹងហើយ។

ក៖ ធ្លាប់ច្រៀងធ្លាប់អីច្រៀងលេង?

ខ៖ ច្រៀងលេងជាមួយគេជាមួយឯងអញ្ចឹងទៅ ដូចថាអង្គការឱ្យខ្ញុំទៅអញ្ចឹងទៅច្រៀងលេងអញ្ចឹងទៅហ្នឹងហើយ។

ក៖ ហើយអ្នកមីងសព្វថ្ងៃរករបរតែមួយហ្នឹងទេ? លក់ត្រី?

ខ៖ ខ្ញុំរកតែរបរលក់ត្រីបេះត្រកួនបេះផ្ទីអីអញ្ចឹងទៅ។

ក៖ ចាំស! អ្នកមីងចេះជំនាញអ្វីផ្សេងក្រៅពីលក់ត្រី?

ខ៖ ខ្ញុំអត់ចេះជំនាញអ្វីក្រៅពីលក់ត្រីទេ កូនអើយខ្ញុំចេះតែលក់ត្រីបេះត្រកួនលក់ បេះអីអញ្ចឹងទៅ។

ក៖ ដូចថាអត់ចេះធ្វើជំនួញអ្វីផ្សេងទៀតទេអ្នកមីងណោះ?

ខ៖ អត់ចេះទេ!

ក៖ ចុះអ្នកវិញគិតថាពីមុនមកដល់ឥឡូវពេលណាដូចថាពិបាកជាងទៅអ្នកមីង? ដូចថាជំនាន់មុនហើយជំនាន់ឥឡូវនេះ?

ខ៖ ជំនាន់នេះជំនាន់ឥឡូវហេ៎?

ក៖ ចាំ!

ខ៖ ជំនាន់ឥឡូវយើងដូចថាកាលពីមុនខ្ញុំពិបាកពីអាពត ពី លន់ នល់ ពិបាកហើយអស់ហើយពិបាកវេទនាសព្វគ្រប់អស់ហើយណាំ ដល់ពេលជំនាន់ឥឡូវនេះខ្ញុំអត់សូវពិបាកប្រវែងមែនទេព្រោះអីយើងមានដូចថាកូនចៅបានរៀនបានសូត្រអ្វីគ្រប់គ្នាអញ្ចឹងទៅហ្នឹងហើយ កាលពីជំនាន់ប៉ុលពតយើងអត់បានរៀនអត់បានសូត្រអីទេដល់ជំនាន់សម្តេចហ៊ុនសែន យើងឥឡូវនេះដូចថាគាត់ឲ្យមានសាលារៀនមានផ្លូវមានអ្វីឲ្យកូនចៅទៅបានរៀនបានសូត្រអី ។

កៈ ចាំសៗ!

ខៈ ហ្នឹងហើយ!

កៈ
ចុះអ្នកមីងគិតថាតាំងពេលនៅក្មេងមកធ្លាប់សង្ឃឹមពីបំណងរបស់អ្នកមីងមកដល់ឥឡូវមានធ្លាប់បានសម្រេចបំណងប្រាថ្នាអីដែរ ឬក៏អត់អ្នកមីង?

ខៈ ខ្ញុំហេ៎?

កៈ ចាំស!

ខៈ
ថាយ៉ាងម៉េចម្ដងម្កាលឲ្យជួយថាឲ្យបានកូនចៅអីរៀនសូត្រមានអីឱ្យបានមានអនាគតទៅមុខអីល្អអញ្ចឹងទៅណាហ្នឹងហើយ។

កៈ អ្នកមីងមានបទពិសោធន៍ណាល្អៗ
ធ្លាប់ឆ្លងកាត់ដែលចង់ចែកដូចថាចង់ផ្ដល់ទៅឱ្យកូនចៅរបស់មីងជំនាន់ក្រោយ?

ខៈ ខ្ញុំហេ៎?

កៈ ចាំស! បទពិសោធន៍អ្វី ដែលល្អៗនៅក្នុងជីវិតរបស់អ្នកមីងអញ្ចឹងណា៎?

ខៈ បទពិសោធន៍ដែលល្អដូចថាឱ្យកូនចៅខំប្រឹងរៀនសូត្រយកតម្រិះខ្លួនឯងអញ្ចឹងទៅ
ព្រោះឥឡូវគេមានរៀនភាសាអីអញ្ចឹងទៅគេមានអង្គការខាងជួយឲ្យយើងធ្វើការធ្វើវាឲ្យទៅណា៎
មិនដូចកាលពេលមីងពីជំនាន់មីងទេហ្នឹងហើយបានជួយឱ្យកូនជួយឲ្យរៀនខំប្រឹងរៀនសូត្រទៅធ្វើយ៉ាងម៉េចឲ្យតែបានចេះបានធ្វើការធ្វើងារព្រោះសព្វថ្ងៃនេះគេរកតែអ្នកចេះទេ។

កៈ ចាំស!

ខៈ ហ្នឹងហើយ! មួយជំនាន់ខ្ញុំមកវាលំបាកវេទនាអស់ហើយ
បើក្មេងឥឡូវវាមិនលំបាកទេគេមានម៉ែឪគ្រប់គ្រងហើយមានសាលារៀនមានអីអញ្ចឹងមានអ្វីគ្រប់គ្រាន់អញ្ជើញទៅណាមានផ្លូវមានអីមានកង់មានអីជិះហើយសព្វថ្ងៃនេះនោះ។
វាមិនពិបាកដូចជំនាន់ខ្ញុំពីមុនទេក្មេងៗឥឡូវនេះនោះហ្នឹងហើយ។

កៈ អ្នកមីងមានអ្វីចង់ប្រើផ្ដាំផ្ញើរទៅកាន់កូនចៅរបស់អ្នកមីងជាមុនក្រោយទៀតទេ?

ខ៖ ខ្ញុំហេ៎?

ក៖ ចា៎ស!

ខ៖
ខ្ញុំចង់ផ្ដាំផ្ញើរកូនចៅរបស់ខ្ញុំឲ្យរៀនសូត្រឲ្យបានដើរតាមផ្លូវល្អកុំឱ្យមានជក់ជៀសផុតរឿងគ្រឿងញៀនគ្រឿងអីអញ្ចឹងណា៎។

ក៖ ចា៎!

ខ៖ ហ្នឹងហើយ។ សូមឱ្យសម្ដេចជួយកូនចៅទាំងអស់។
កុំឱ្យជក់គ្រឿងញៀនជួបរឿងអីហ្នឹងណា៎។

ក៖ ចា៎សៗ!

ខ៖ ហ្នឹងហើយ។

ក៖ ព្រោះសង្គមយើងឥឡូវសម្បូរគ្រឿងញៀន។

ខ៖ សង្គមឥឡូវសម្បូរគ្រឿងញៀន ទាំងស្រីទាំងប្រុស។

ក៖ ចា៎ស!

ខ៖ ហ្នឹងហើយសម្បូរ។

ក៖ សម្បូរខ្លាំងណាស់។

ខ៖ សម្បូរណាស់!

ក៖
អើយអ្នកមីងខ្ញុំសូមអរគុណអ្នកមីងដែលបានអនុញ្ញាតឲ្យខ្ញុំសម្ភាសអ្នកមីងនៅក្នុងថ្ងៃហ្នឹងហើយការសម្ភាសនេះត្រូវបានដាក់បញ្ចូលទៅក្នុងគេហទំព័ររបស់សាលាសាកលវិទ្យាល័យbyuរបស់សហរដ្ឋអាមេរិកអ្នកមីងណា៎។

ខ៖ ចា៎ស!

ក៖ ហើយសូមអរគុណអ្នកមីងដែលបានអនុញ្ញាតឲ្យខ្ញុំសម្ភាសនៅក្នុងថ្ងៃនេះ។

ខ៖ ចា៎ស!